# វកជាតក

## (រឿងឧបោសថរបស់ឆ្កែព្រៃ)



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**គុល ផេង** **ព.ស. ២៥៦៤**

# វកជាតក

រៀបរៀងដោយ

បណ្ឌិត **កុល ផេង**


សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **ទកជាតក** |
| រៀបរៀងដោយ | បណ្ឌិត **គុល ផេង**<br>ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃអង្គារ ១៤ រោច ខែ<br>ស្រាពណ៍ ឆ្នាំជូត<br>ទោស័ក ព.ស. ២៥៦៤<br>ថ្ងៃទី ១៨ ខែ សីហា គ.ស.<br>២០២០ |

# វកជាតក

## បុព្វនិទានជាដើមហេតុនៃជាតក

*សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីនឹងលាក់ខ្លួនសម្ងំបានបីខែ អ្នកណាមួយកុំគប្បីចូលទៅរកតថាគត លើកលែងតែភិក្ខុ ១ រូប ដែលជាអ្នកនាំយកនូវបិណ្ឌបាតទៅឲ្យ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ភិក្ខុណានីមួយមិនបានចូលមករកព្រះដ៏មានព្រះភាគក្នុងទីនេះជាប្រាកដ លើកលែងតែភិក្ខុ ១ រូបដែលជាអ្នកនាំយកបិណ្ឌបាតទៅថ្វាយ ។*

*ក៏វេលានោះឯង សង្ឃក្នុងក្រុងសាវត្ថីបានប្ដេជ្ញាគ្នាថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ប្រាថ្នាដើម្បីនឹងសម្រាកព្រះអង្គនៅបានបីខែ ភិក្ខុណាមួយកុំគប្បី*

ចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុ ១ រូបដែលជាអ្នកនាំយកបិណ្ឌបាត ទៅថ្វាយនោះ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះសម្តែងអាបត្តិបាចិត្តិយៈចេញ ។

គ្រានោះ ភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុព្រមដោយបរិសទ្យ បានចូលទៅគាល់សម្តេចព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយបាន ថ្វាយបង្គំគាល់ព្រះអង្គក្នុងទីដ៏សមគួរ ។ សេចក្តីស្រុះស្រួលពាក់ទាក់មួយ អន្ទើដោយពួកអាគន្តុកភិក្ខុនេះ ជាកិច្ច[១]ដែលព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់ប្រព្រឹត្តសន្សំទុកមកហើយ ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពាក្យនេះ នឹងឧបសេនភិក្ខុវង្គន្តបុត្រ ដ៏មានអាយុថា ម្នាលឧបសេនអ្នករាល់គ្នាល្មមធន់ទ្រាំបានដែរឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលដែរឬ អ្នករាល់គ្នាដើរផ្លូវឆ្ងាយ

---

[១]. ធម្មនិយាមទី ២៦. **អាគន្តុកេហិ ភិក្ខូហិ បដិសន្ថារការណំ** ទ្រង់ធ្វើបដិសណ្ឋារៈនឹងភិក្ខុអាគន្តុកៈ ។

មកមិនលំបាកទេឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមធន់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួល ម្យ៉ាងទៀត បពិត្រព្រះអង្គដ៏ចម្រើនយើងខ្ញុំទាំងឡាយ ដើរផ្លូវឆ្ងាយមកមិនបានលំបាកទេ ។

ក៏សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ឧបសេនវង្គន្តបុត្រដ៏មានអាយុអង្គុយជិត ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរ ភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ បង្សុកូលទាំងឡាយជាទីគាប់ចិត្តរបស់អ្នកដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បង្សុកូលទាំងឡាយ មិនជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គទេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ក៏អ្នកប្រព្រឹត្តបង្សុកូល ( នោះ ) ដើម្បីអ្វី ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ( ព្រោះ ) ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គប្រព្រឹត្តបង្សុកូល ខ្ញុំព្រះអង្គក៏ត្រូវប្រព្រឹត្ត

បង្សុកូលយ៉ាងនោះដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុយ៉ាងនេះថា ម្នាលឧបសេន បរិសទ្យរបស់អ្នកនេះប្រកបដោយសេចក្តីជ្រះថ្លា ម្នាលឧបសេន អ្នកទូន្មានបរិសទ្យដូចម្តេច ។ ឧបសេនភិក្ខុដ៏មានអាយុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រណាមកសូមឧបសម្បទានឹងខ្ញុំព្រះអង្គ ៗ រមែងប្រាប់កុលបុត្រនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល បើអ្នកនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូលដែរ ខ្ញុំនឹងឲ្យអ្នកបានឧបសម្បទា បើអ្នកណាទទួលស្តាប់ខ្ញុំព្រះអង្គ ៗ នឹងឲ្យអ្នកនោះបានឧបសម្បទា បើអ្នកណាមិនទទួលស្តាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឲ្យអ្នកនោះបានឧបសម្បទាទេ អ្នកណាសូមនិស្ស័យនឹងខ្ញុំព្រះអង្គ ៗ នឹងប្រាប់អ្នកនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល បើអ្នក

ឯងនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូលដែរ ខ្ញុំនឹងឲ្យនិស្ស័យ ដល់អ្នក បើអ្នកណាទទួលស្តាប់ខ្ញុំព្រះអង្គៗ នឹងឲ្យនិស្ស័យដល់ អ្នកនោះ បើមិនទទួលស្តាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិន ឲ្យនិស្ស័យដល់អ្នកនោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ ព្រះអង្គរមែងណែនាំបរិសទ្យ ដោយអាការយ៉ាងនេះ ឯង ។ ព្រះដ៏មានព្រះភាគត្រាស់ប្រទានពរសាធុការថា ឧបសេនល្អហើយៗ ឧបសេន អ្នកណែនាំបរិសទ្យល្អ ពិតហើយ ឧបសេន អ្នកដឹងសេចក្តីប្តេជ្ញារបស់សង្ឃ ក្នុងក្រុងសាវត្ថីដែរឬទេ ។ ឧបសេនភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គមិនបានដឹងសេចក្តី ប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ។ ព្រះដ៏មានព្រះ ភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សង្ឃបានប្តេជ្ញា ហើយក្នុងក្រុងសាវត្ថីថា អាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ ប្រាថ្នាដើម្បីនឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែង តែភិក្ខុ១រូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយ ភិក្ខុណា

ចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃគប្បីឲ្យភិក្ខុនោះសម្ដែង
អាបត្តិបាចិត្តិយៈចេញ ។ ភិក្ខុឧបសេន ក្រាបទូលថា
បពិត្រព្រះអង្គដ៏ចម្រើន សង្ឃក្នុងក្រុងសាវត្ថីបាន
បញ្ញត្តដោយសេចក្ដីប្ដេជ្ញារបស់ខ្លួន ខ្ញុំព្រះអង្គទាំង
ឡាយនឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់
បានបញ្ញត្តទេ ម្យ៉ាងទៀត នឹងមិនដកចេញនូវសិក្ខា-
បទ ដែលទ្រង់បានបញ្ញត្តទុកហើយទេ នឹងប្រព្រឹត្ត
កាន់យកតាមសិក្ខាបទដែលទ្រង់បញ្ញត្តទុកមកហើយ ។
ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ល្អណាស់ហើយ
ឧបសេន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទដែលតថាគត
មិនទាន់បានបញ្ញត្តហើយ ម្យ៉ាងទៀតមិនត្រូវដកនូវ
សិក្ខាបទដែលតថាគតបញ្ញត្តហើយ ត្រូវប្រព្រឹត្តកាន់
យកតាមសិក្ខាបទដែលតថាគតបានបញ្ញត្តទុកហើយ
ឧបសេន តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ
អ្នកប្រព្រឹត្តបិណ្ឌបាត នឹងប្រព្រឹត្តបង្សុកូលចូលទៅរក
តថាគតតាមសប្បាយចុះ ។

*ក៏គ្រានោះឯង ភិក្ខុច្រើនរូបឈរនៅជិតក្លោងទ្វារខាងក្រៅបាននិយាយគ្នាថា យើងទាំងឡាយ ត្រូវឲ្យលោកឧបសេនវង្គន្តបុត្រដ៏មានអាយុសម្ដែងអាបត្តិបាចិត្តិយៈចេញ ។ វេលានោះ ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុព្រមទាំងបរិសទ្យ ក្រោកចេញចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ភិក្ខុទាំងនោះបាននិយាយពាក្យនេះនឹងឧបសេនវង្គន្តបុត្រដ៏មានអាយុក្នុងវេលានោះថា អាវុសោឧបសេន អ្នកដឹងសេចក្ដីប្ដេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីដែរឬ ។ ឧបសេនភិក្ខុបាននិយាយតបថា អាវុសោ ព្រះដ៏មានព្រះភាគក៏បានត្រាស់សួរខ្ញុំយ៉ាងនេះថា ម្នាលឧបសេន អ្នកបានដឹងសេចក្ដីប្ដេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គមិនបានដឹងសេចក្ដី ប្ដេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សេចក្ដីប្ដេជ្ញាសង្ឃបានធ្វើហើយក្នុងក្រុងសាវត្ថីថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់*

ប្រាជ្ញានឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុណា
មួយកុំគប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ លើក
លែងតែភិក្ខុ ១ រូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយ
ប៉ុណ្ណោះ ភិក្ខុណាចូលទៅគាល់ព្រះដ៏មានព្រះភាគ
ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះសម្ដែងអាបត្តិបាចិត្តិយៈចេញ
ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឃក្នុងក្រុង
សាវត្ថី បានបញ្ញត្តដោយសេចក្ដីប្ដេជ្ញារបស់ខ្លួន ខ្ញុំព្រះ
អង្គទាំងឡាយនឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិន
ទាន់បានបញ្ញត្ត ម្យ៉ាងទៀត នឹងមិនដកនូវពុទ្ធប្បញ្ញត្តិ
ដែលព្រះអង្គបានបញ្ញត្តទុក ស្រេចហើយនឹងប្រព្រឹត្ត
កាន់យកតាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុក
មកហើយ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់
អនុញ្ញាតហើយថា ភិក្ខុទាំងឡាយណាជាអ្នកប្រព្រឹត្ត
នៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្ត
បង្សុកូល ភិក្ខុទាំងឡាយនោះចូលមករកតថាគតតាម
សប្បាយចុះ ។

គ្រានោះ ភិក្ខុទាំងនោះបានពោលថា ឧបសេន ភិក្ខុវង្គន្តបុត្រដ៏មានអាយុ បានពោលពាក្យពិតមែន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទដែលព្រះអង្គមិនទាន់ បានបញ្ញត្ត ម្យ៉ាងទៀត មិនត្រូវដកនូវសិក្ខាបទដែល ព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ត្រូវប្រព្រឹត្តកាន់យក តាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ។

ភិក្ខុទាំងឡាយបានឮ (ដំណឹង) ថា ឮថាព្រះដ៏ មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត អ្នកប្រព្រឹត្តបង្សុកូល ចូលទៅរក តថាគតតាមសប្បាយចុះ ។ ភិក្ខុទាំងនោះកាលប្រាថ្នា នឹងឃើញព្រះដ៏មានព្រះភាគ ទើបលះចោលនូវសន្ថ័ត ទាំងឡាយ ហើយសមាទានអារញ្ញកង្គធុតង្គ បិណ្ឌបា-តិកង្គធុតង្គ និងបង្សុកូលិកង្គធុតង្គ ។

កាលព្រះមានព្រះភាគទ្រង់ចេញចាកទីពួន សម្ងំហើយ ភិក្ខុទាំងឡាយដែលជាអ្នកសមាទានធុតង្គ ព្រោះចង់ចូលគាល់ព្រះមានព្រះភាគនោះ ក៏នាំគ្នា

បោលសំពត់បង្សុកូលទាំងឡាយក្នុងទីកន្លែងផ្សេងៗ ឈប់សមាទានធុតង្គ ហើយកាន់យកបាត្រនិងចីវរ របស់ខ្លួនវិញ ។

ព្រះសាស្ដាយាងទៅកាន់សេនាសនៈចារិក ជាមួយភិក្ខុទាំងឡាយ ទ្រង់ទតឃើញសំពត់បង្សុកូល ទាំងឡាយនៅរាត់រាយពាសវាលពាសកាល ទើបទ្រង់ ត្រាស់សួរភិក្ខុទាំងឡាយ ទ្រង់បានស្ដាប់រឿងនោះហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការសមាទានធុតង្គ របស់ភិក្ខុទាំងនេះ ជារបស់មិនតាំងនៅយូរអង្វែង ដូច ឧបោសថកម្មរបស់ខ្មែព្រៃដូច្នោះ ហើយទ្រង់នាំយក អតីត មកសម្ដែងថា

## អតីតនិទាន

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយ រាជសម្បត្តិក្នុងនគរពារាណសី, ក្នុងកាលនោះ ព្រះ ពោធិសត្វ ទ្រង់ជាសក្កទេវរាជ ។

ក្នុងកាលនោះ មានខ្លែងព្រៃមួយរស់នៅលើផ្ទាំងថ្ម ដែលនៅនឹងច្រាំងស្ទឹងគង្គា ។ បន្ទាប់មក ជំនន់ទឹកដ៏ធំក្នុងស្ទឹងគង្គាជន់មកទល់គ្នាជុំវិញថ្មដានោះ ។ ខ្លែងព្រៃក៏ឡើងទៅដឹកលើផ្ទាំងថ្ម, ទីស្វែងរកអាហារ និងផ្លូវដែលស្វែងរកអាហាររបស់ខ្លែងព្រៃនោះ មិនមានស្ទឹងក៏ពោរពេញទៅដោយទឹក ។ ខ្លែងព្រៃគិតថា “អញមិនមានកន្លែងស្វែងរកអាហារ ផ្លូវដែលនឹងទៅស្វែងរកអាហារ ក៏មិនមាន ឧបោសថកម្មជារបស់ប្រសើរជាងការដេករបស់អញដែលទំនេរ” រួចហើយក៏អធិដ្ឋានឧបោសថដោយចិត្តប៉ុណ្ណោះ សមាទានសីលហើយដេក ។

ក្នុងកាលនោះ សក្កទេវរាជទ្រង់ពិចារណាមើលទ្រង់ជ្រាបការសមាទានដែលទន់ខ្សោយរបស់ខ្លែងព្រៃនោះ ទ្រង់ត្រិះរិះថា អញនឹងសាកល្បងខ្លែងព្រៃនេះ ហើយទ្រង់និម្មិតខ្លួនជាពពែ យាងមកឈរសម្តែងខ្លួនឲ្យខ្លែងព្រៃឃើញ ក្នុងទីមិនឆ្ងាយអំពីខ្លែងព្រៃនោះ ។ ខ្លែងព្រៃឃើញពពែហើយគិតថា “អញនឹងការរក្សា

ឧបោសថកម្មក្នុងថ្ងៃដទៃចុះ" ហើយក្រោកឡើង ស្ទុះទៅ ដើម្បីចាប់ពពែនោះស៊ី ។ ពពែរត់ទៅខាងនេះខាងនោះ មិនឲ្យខ្លែព្រៃចាប់បាន ។ ខ្លែព្រៃកាលមិនអាចចាប់ពពែបាន ក៏ត្រឡប់មកដេកលើផ្ទាំងថ្មវិញ ហើយគិតថា ឧបោសថកម្មរបស់អញមិនទាន់ដាច់ទេ ។ សក្កទេវរាជទ្រង់ប្រថាប់ឈរលើអាកាសដោយអានុភាពរបស់ខ្លួន ទ្រង់តិះដៀលខ្លែព្រៃនោះថា "ប្រយោជន៍អ្វីដោយឧបោសថកម្មរបស់បុគ្គលដែលមានអធ្យាស្រ័យទន់ខ្សោយដូចអ្នកនោះ អ្នកមិនដឹងថា យើងជាសក្កទេវរាជ ទើបប្រាថ្នាស៊ីសាច់ពពែ" លុះទ្រង់តិះដៀលខ្លែព្រៃនោះហើយ ទ្រង់ចៀសចេញទៅ ។

ព្រះសុគតទ្រង់ត្រាស់ថា

**បរបាណឃាតោ ជីវន្តា, មំសលោហិតភោជនោ;**
**វត្តោ វតំ សមាទាយ, ឧបបជ្ជិ ឧបោសថំ។**

ខ្លែព្រៃកាលរស់នៅ មានសាច់និងឈាមជាភោជន ព្រោះសម្លាប់តែអ្នកដទៃ ( ហើយអួតថា ) សមាទាននៅវត្តរក្សានូវឧបោសថ ។

តស្ស សក្កោ វិតញ្ញាយ, អជរូបេនុបាគមិ;
វីតតបោ អជ្ឈប្បត្តោ, ភញ្ជិ លោហិតបោ តបំ។

សក្កទេវរាជ បានដឹងច្បាស់នូវវត្តរបស់ខ្លែព្រៃនោះ ហើយចូរមកដោយ ( ក្លែងខ្លួន ) ជារូបពពែ ខ្លែព្រៃមានតបៈ ទៅប្រាសហើយជាសត្វផឹកនូវឈាម ( នៃសត្វដទៃ ) បានស្ទុះចូរទៅ ( ដើម្បីខាំពពែស៊ី ) ហើយទម្លាយបង់នូវតបៈ ដែលខ្លួនសមាទានហើយ ។

ឯវមេវ ឥធេកច្ចេ, សមាទានម្ហិ ទុព្ពលា;
លហុំ ករោន្តិ អត្តានំ, វកោវ អជការណា។

បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានកម្លាំងថយ ក្នុងការសមាទាន ឈ្មោះថា ធ្វើខ្លួនឲ្យរហ័ស ដូច

ជាឆ្កែព្រៃ (ដែលទម្លាយនូវតបៈរបស់ខ្លួន) ព្រោះហេតុតែពពែ ក៏យ៉ាងនោះឯង ។

## ជាតកភាវសាន

ព្រះសាស្តានាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

តទា សក្កោ អហមេវ អហោសិំ សក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

វកជាតក ចប់ ។

(វិនយបិដក មហាវិភង្គ, ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត កុម្ភវគ្គ វកជាតក)



# សីលធំនេះ

ឯវមេវ ឥធេកច្ចេ, សមាទានម្ហិ ទុព្ពលា;
លហុំ ករោន្តិ អត្តានំ, វកោវ អជករណោ។

បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានកម្លាំងថយ ក្នុងការសមាទាន ឈ្មោះថា ធ្វើខ្លួនឲ្យរហ័ស ដូចជាឆ្កែព្រៃ ( ដែលទម្លាយនូវតបៈរបស់ខ្លួន ) ព្រោះហេតុតែពពែ ក៏យ៉ាងនោះឯង ។